ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០១ រ៉ែ-ប.ល.សជណ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាសម្រាប់បម្រើការងារនៅទីស្ដីការក្រសួង និងតាមមន្ទីររ៉ែ និងថាមពលរាជធានីខេត្តសម្រាប់ឆ្នាំ ២០១៧

ក្រសួងរ៉ែ និងថាមពល មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណៈជន និងមន្ត្រីជាប់កិច្ចសន្យាដែលធ្លាប់បម្រើការងារនៅទីស្ដីការក្រសួង និងនៅតាមបណ្ដាមន្ទីររ៉ែ និងថាមពលរាជធានីខេត្ត ក្នុងឆ្នាំ២០១៦ ជ្រាបថា សម្រាប់ឆ្នាំ២០១៧នេះ ក្រសួងរ៉ែ និងថាមពល ត្រូវការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាចំនួន ២០០ កន្លែង ឲ្យចូលបម្រើការងារនៅទីស្ដីការក្រសួង និងនៅតាមមន្ទីររ៉ែ និងថាមពលរាជធានីខេត្ត នូវតម្រូវការដូចខាងក្រោម៖

១.មន្ត្រីជាប់កិច្ចសន្យា ជាអ្នកសំអាត អ្នកបើកបរ និងជំនួយការថ្នាក់ដឹកនាំ

២.មន្ត្រីជាប់កិច្ចសន្យា ជាសន្តិសុខ

៣.មន្ត្រីជាប់កិច្ចសន្យាដែលមានជំនាញខាងរដ្ឋបាល សេដ្ឋកិច្ច និងគណនេយ្យ ច្បាប់ គ្រប់គ្រងនិងមុខជំនាញពាក់ព័ន្ធនឹងថាមពល រ៉ែ និងប្រេងកាត

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណៈជន និងមន្ត្រីជាប់កិច្ចសន្យាដែលធ្លាប់បម្រើការងារនៅឆ្នាំ២០១៦ អញ្ជើញមកដាក់ពាក្យស្នើសុំ នៅនាយកដ្ឋានបុគ្គលិកចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកចាប់ពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:៣០ នាទី ដល់ម៉ោង១៧:០០ នាទី។

បញ្ជាក់ ៖ ពាក្យស្នើសុំចូលជាមន្ត្រីជាប់កិច្ចសន្យាអាចទាញយកតាមរយៈគេហទំព័រ www.mme.gov.kh និងតាម facebook.com/MMECambodia។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧

ស៊ុយ សែម

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh